NEWS RELEASE

UNITED NATIONS HUMAN RIGHTS SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# ប្រទេសកម្ពុជា៖ អ្នកជំនាញផ្នែកសិទ្ធិមនុស្សរបស់ អ.ស.ប. អំពាវនាវឱ្យ "មានការរៀបចំឡើងវិញ" ដោយផ្តោតលើប្រជាជនជាចម្បង

ទីក្រុងហ្សឺណែវ (ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩)៖ អ្នកជំនាញផ្នែកសិទ្ធិមនុស្សរបស់ អ.ស.ប. បានសម្តែងកង្វល់ទៅលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងប្រទេសកម្ពុជា ដែលរាប់បញ្ចូលទាំង ការហាមឃាត់ទៅលើគណបក្សជំទាស់ដ៏ធំ ហើយអំពាវនាវឱ្យរដ្ឋាភិបាលរៀបចំចំណាត់ការឡើងវិញ ដើម្បីធានាឱ្យមានសង្គមមួយប្រកបដោយបរិយាប័ន្នពេញលេញផ្អែកលើគោលការណ៍ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។

អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នកស្រី រ៉ូណា ស្មីត បានមានប្រសាសន៍ថា "វាដល់ពេលវេលាដែលត្រូវរៀបចំអភិក្រមសាឡើងវិញទាក់ទងនឹងសិទ្ធិ និងសេរីភាព នៅប្រទេសកម្ពុជា និងត្រូវធានាថាជនគ្រប់រូបនៅក្នុងប្រទេសកម្ពុជាទទួលបាននូវសិទ្ធិ និងសេរីភាពទាំងអស់ដែលរដ្ឋាភិបាលបានទទួលយកដោយស្ម័គ្រចិត្ត"។

"ផ្អែកលើនិយមន័យ សិទ្ធិមនុស្សគឺផ្តោតទៅលើមនុស្ស មិនមែនទៅលើរឿងនយោបាយនោះទេ"។

អ្នកស្រីបានបន្តមានប្រសាសន៍ទៀតថា "ការបោះឆ្នោត និងសំឡេងឆ្នោតគាំទ្រគណបក្សសង្គ្រោះជាតិ ចំនួន ៤២ ភាគរយ នៃចំនួនប្រជាជនសរុប ដែលទទួលបាននៅក្នុងអំឡុងពេលនៃការបោះឆ្នោតថ្នាក់ឃុំ-សង្កាត់ នៅតែត្រូវបានបដិសេធ និងមិនទាន់ត្រូវបានដោះស្រាយនៅឡើយ"។

អ្នកជំនាញការឯករាជ្យរូបនេះបានគូសបញ្ជាក់សាជាថ្មីអំពីសេចក្តីអំពាវនាវរបស់អ្នកស្រីឱ្យមានការដោះលែងមេដឹកនាំគណបក្សជំទាស់គឺ លោក កឹម សុខា ចេញពីការឃុំខ្លួនមុនការជំនុំជម្រះ និងការបិទបញ្ចប់ការស៊ើបសួរឱ្យបានឆាប់រហ័សទៅលើសំណុំរឿងរបស់គាត់ ដើម្បីធានាឱ្យមានការគោរពសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលធ្វើឡើងក្នុងរយៈពេលសមស្រប ឬត្រូវទម្លាក់ចោលរាល់បទចោទទាំងអស់។

អ្នកស្រី ស្មីត ក៏បានលើកឡើងអំពីការចាប់ខ្លួន និងការចេញដីកាកោះហៅអតីតសមាជិករបស់

គណបក្សលោក កឹម សុខា ចំនួនជាង ១០០ នាក់ នាពេលថ្មីៗនេះ ដោយសារពួកគេត្រូវបាន ចោទប្រកាន់ពីបទល្មើសពាក់ព័ន្ធនឹងការចូលរួមពិភាក្សារឿងនយោបាយ ឬសកម្មភាព ទាំងឡាយដែលត្រូវបានចាត់ទុកថាផ្ទុយនឹងសាលដីការំលាយគណបក្សសង្គ្រោះជាតិ ដែល សម្រេចដោយតុលាការកំពូល កាលពីខែ វិច្ឆិកា ឆ្នាំ២០១៧។ "ដីកាកោះ និងបទចោទប្រឆាំង នឹងប្រជាជនទាំងនេះត្រូវបានធ្វើឡើងក្នុងលក្ខណៈទូលាយ និងមិនច្បាស់លាស់ ដែលញ៉ាំងឱ្យ មានការព្រួយបារម្ភចំពោះសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពខាងសមាគម សិទ្ធិនយោបាយ ព្រមទាំងសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌"។

ទោះបីជាអ្នករាយការណ៍ពិសេសបានសម្តែងការស្វាគមន៍ចំពោះការលុបចោលលក្ខខណ្ឌ តម្រូវឱ្យអង្គការសង្គមស៊ីវិលត្រូវធ្វើការជូនដំណឹងចំនួនបីថ្ងៃមុននឹងរៀបចំកម្មវិធីរបស់ខ្លួន ក៏ដោយ ក៏អ្នកស្រីនៅតែសម្តែងកង្វល់ជាខ្លាំងចំពោះការឃ្លាំមើលរបស់អាជ្ញាធរមូលដ្ឋានទៅ លើកម្មវិធី និងសកម្មភាពការងាររបស់សង្គមស៊ីវិលទាំងនោះ។

អ្នកស្រីអំពាវនាវឱ្យគ្រប់ភាគីនយោបាយទាំងអស់ផ្តោតការយកចិត្តទុកដាក់ទៅលើការពិភាក្សា បែបស្ថាបនាអំពីគោលនយោបាយ និងកម្មវិធីផ្សេងៗ ជាជាងការផ្តោតតែទៅលើលក្ខណៈ របស់បុគ្គល ក្នុងការប្រើប្រាស់ធ្វើជាមធ្យោបាយដ៏ប្រសើរបំផុតដើម្បីទទួលបានសន្តិភាព និង ការអភិវឌ្ឍប្រកបដោយចីរភាព។

លោកស្រី ស្មីត បានលើកឡើងពីការប្តូរឲ្យទៅរស់នៅលើដីគោករបស់សហគមន៍បណ្តែតទឹក របស់ជនជាតិវៀតណាម នៅខេត្តកំពង់ឆ្នាំង ហើយក៏បានផ្តល់អនុសាសន៍ថា អាជ្ញាធរពាក់ព័ន្ធ គួរធានាថាលក្ខខណ្ឌទាំងឡាយនៃការផ្លាស់ប្តូរឲ្យទៅរស់នៅលើគោកត្រូវស្របតាមបទដ្ឋាន សេដ្ឋកិច្ច និងសង្គម។

សិទ្ធិរបស់ជនដែលមានពិការភាពនៅក្នុងមណ្ឌលឃុំឃាំង និងមណ្ឌលស្តារនីតិសម្បទា គឺជា បញ្ហាគួរឲ្យកង្វល់មួយផ្សេងទៀត។ "ជនដែលមានពិការភាព ជាពិសេស ជនពិការផ្លូវចិត្ត មិន គួរត្រូវបានដកហូត សេរីភាព ដោយផ្អែកលើពិការភាពរបស់ពួកគេនោះទេ" អ្នកស្រី ស្មីត បាន មានប្រសាសន៍ដូច្នេះនៅពេលលើកឡើងពីស្ថានភាពរបស់ជនមានមនសិការវិកល និងជន មានពិការភាព ក្នុងមជ្ឈមណ្ឌលថែទាំ និងស្តារនីតិសម្បទាជនវិបល្លាសស្មារតី ក្នុងខេត្តកណ្តាល។

អ្នកស្រី ស្មីត បានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តរបស់អ្នកស្រីក្នុងការធ្វើការជាមួយរដ្ឋាភិបាល សង្គមស៊ីវិលនិងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីពង្រឹងការការពារ ការលើកស្ទួយ និងការគោរព

សិទ្ធិមនុស្សនៅក្នុង ព្រះរាជាណាចក្រ។

អ្នកស្រី ស្មីត បានជម្រាបដល់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ថា "ការបញ្ជាក់មួយកាន់តែច្បាស់ថែមទៀត អំពីសិទ្ធិមនុស្សនៅក្នុងក្របខណ្ឌអភិវឌ្ឍន៍យុទ្ធសាស្ត្ររបស់រដ្ឋាភិបាល និងសកម្មភាពជាក់ស្តែង នឹងជួយគាំទ្រដល់ការអភិវឌ្ឍយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជា ដើម្បីឲ្យក្របខណ្ឌ និងសកម្មភាពទាំងនេះ មានលក្ខណៈបរិយាប័ន្ន សន្តិភាព និងយុត្តិធម៌ ដោយមិនទុកនរណាម្នាក់ចោល"។

ចប់

***អ្នកជំនាញ អ.ស.ប៖ សាស្ត្រាចារ្យ រ៉ូណា ស្មីត*** *(ចក្រភពអង់គ្លេស) អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។*

*អ្នករាយការណ៍ពិសេស ពួកគាត់គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញ ឯករាជ្យ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយធ្វើការឯករាជ្យពីរដ្ឋាភិបាល និង អ.ស.ប។ ពួកគាត់បំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។*

*ពិនិត្យមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីប្រទេសកម្ពុជា និង មើលទំព័រហ្វេសប៊ុករបស់អ្នករាយការណ៍ពិសេស៖*
*https://www.facebook.com/SpecialRapporteurCambodia/?modal=admin_todo_tour*
*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រសម្រាប់ប្រទេស៖ កម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង៖*

*លោកស្រី អ៊ីស្ទឺរ ឡាំ (Esther Lam) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩២៨ ៩១ ០៨ ឬ អ៊ីម៉ែល elam@ohchr.org ម៉ាសម៉ូដ ហ្គារហ្គា តាមរយៈទូរស័ព្ទ៖ (+៨៥៥ (0)១២ ៧៩០ ១៧៨ អ៊ីម៉ែល mgarga@ohchr.org )*

*សម្រាប់ការសាកសួរព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖*
*លោក ហ្សេរ៉េមី ឡូរ៉េង់ស៍ (Jeremy Laurence) សិទ្ធិមនុស្ស អ.ស.ប– អង្គភាពប្រព័ន្ធផ្សព្វផ្សាយ តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៣៨៣ ឬ អ៊ីម៉ែល jlaurence@ohchr.org)*

តើអ្នកមានកង្វល់អំពីពិភពលោកដែលយើងរស់នៅមែនទេ?
ដូច្នេះសូមក្រោកឈរដើម្បីសិទ្ធិរបស់អ្នកណាម្នាក់ នៅថ្ងៃនេះ។

#Standup4humanrights និង ចូលមើលទំព័រវេបរបស់យើង តាម http://www.standup4humanrights.org